វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី០៥ ខែតុលា ២០១៨**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ឧស្សាហកម្មសញ្ញាប័ណ្ណសាជីវកម្មដំបូងរបស់ប្រទេសកម្ពុជា ជម្រុញអោយយកដុល្លារអាមេរិក ជារូបិយប័ណ្ណគោល
- កម្ពុជានាំចូលម៉ូតូពីប្រទេសថៃកាន់តែច្រើន
- ដុល្លារអាមេរិកនៅតែជារូបិយប័ណ្ណរបស់ពិភពលោក តើរហូតដល់ពេលណា?

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ឧស្សាហកម្មសញ្ញាប័ណ្ណសាជីវកម្មដំបូងរបស់ប្រទេសកម្ពុជា ជម្រុញអោយយកដុល្លារអាមេរិក ជារូបិយប័ណ្ណគោល

អ្នកចូលរួមនៅក្នុង សិក្ខាសាលាថ្មីៗនេះស្តីពី អនាគតទីផ្សារមូលប័ត្ររបស់កម្ពុជា (Cambodia's budding securities market) ដែលធ្វើឡើងនៅផ្សារមូលប័ត្រ(CSX) បានអះអាងថា ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកនៅក្នុងពាណិជ្ជកម្ម អាចជួយដល់ទីផ្សារមូលប័ត្រកម្ពុជា និងក្រុមហ៊ុនដែលទីផ្សារផ្តល់មូលនិធិអោយមានការរីកចម្រើនកាន់តែលឿន។

នាយកប្រតិបត្តិមូលប័ត្រមួយចំនួន និងប្រធានប្រតិបត្តិមួយរូបរបស់គណៈកម្មការផ្សារភាគហ៊ុន និងមូលប័ត្រ (SECC) បានសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អោយជួយពិនិត្យមើលគោលនយោបាយទ្រទ្រង់មួយចំនួន ដែលលើកទឹកចិត្តលំហូរនៃប្រាក់ដុល្លារអាមេរិកទៅក្នុងឧស្សាហកម្មនេះ ដោយអះអាងថា ប្រជាជនខ្មែរភាគច្រើនចាយវាយជាដុល្លារអាមេរិក ហើយក្រុមហ៊ុនភាគច្រើនក៏ទូទាត់ជាដុល្លារអាមេរិកដែរ។ ទោះជាយ៉ាងណាក៏ដោយ គោលនយោបាយបែបនេះអាចផ្ទុយគ្នានឹងកិច្ចខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជា ដែលខំជម្រុញការកាត់បន្ថយការប្រើប្រាស់ដុល្លារអាមេរិកនៅក្នុងសេដ្ឋកិច្ច ។

### តារាងប្រចាំសប្តាហ៍៖ វិនិយោគទុនបរទេសហូរទៅក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា

តារាងនៅក្នុងសប្តាហ៍នេះបង្ហាញពីវិនិយោគទុនបរទេសនៅក្នុងវិស័យអចលទ្រព្យ ជាចំណែកជាភាគរយនៃវិនិយោគទុនសរុបនៅកម្ពុជាពី២០១៣ ទៅ២០១៧។ វិនិយោគទុនផ្ទាល់ពីបរទេសបានកើនឡើងតាំងពីឆ្នាំ២០១៣ និងសរុបជាទឹកប្រាក់នៅឆ្នាំ២០១៧ ចំនួន២.០៧១ កោដិរៀល ឬ១៨% នៃវិនិយោគទុនសរុប (equity investment) នៅកម្ពុជា នេះបើយោងទៅតាម ប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ (ITRS) និងធនាគារជាតិនៃកម្ពុជា

**ចំនែកភាគរយនៃវិនិយោគទុនបរទេសនៅក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា ឆ្នាំ២០១៣-២០១៩ (ជាប៊ីលានរៀល)**




ប្រភព៖ ទិន្នន័យ ITRS ដែលប៉ាន់ប្រមាណ របស់ធនាគារជាតិនៃកម្ពុជា

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ប្រទេសកម្ពុជានាំចូលម៉ូតូពីប្រទេសថៃកាន់តែច្រើនឡើង

យោងតាមស្ថិតិចុងក្រោយពី នាយកដ្ឋានគយនៃព្រះរាជាណាចក្រថៃ បានបង្ហាញពីនិន្នាការនៃការបន្តនាំចូលម៉ូតូ របស់កម្ពុជាពីប្រទេសថៃ មានចំនួនកាន់តែច្រើនឡើងៗ។ កម្ពុជាបាននាំចូលម៉ូតូធំ-តូច និងគ្រឿងម៉ាស៊ីនពីប្រទេសថៃ ដោយកើនពី ៥៩ លានដុល្លារក្នុងឆ្នាំ ២០១៦ ទៅ៧៥ លានដុល្លារក្នុងឆ្នាំ ២០១៧។

**ការនាំចូលម៉ូតូរបស់កម្ពុជាដែលមានទឹកប្រាក់ស្មើនឹង៧៥**




**លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៧**

ប្រភព៖ ផែនទីពាណិជ្ជកម្ម និងនាយកដ្ឋានគយនៃប្រទេសថៃ

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### ដុល្លារអាមេរិកនៅតែជារូបិយប័ណ្ណរបស់ពិភពលោក ដល់ពេលណា?

ប្រមាណ២ភាគ៣ នៃបំណុលអន្តរជាតិ និងប្រាក់បំរុងសកល ជាលុយដុល្លារអាមេរិក ដូចបានវាស់វែងកាលពីថ្មីៗនេះដោយធនាគារកណ្តាលអ៊ឺរ៉ុប ។ បន្ថែមពីនេះ ទំនិញភាគច្រើនរបស់ពិភពលោក ត្រូវបានដាក់តម្លៃជាដុល្លារអាមេរិក។

ប៉ុន្តែ ចេតនានៃប្រទេសដ៏ទៃទៀតដែលចង់ធ្វើប្រតិបត្តិការ ដោយដុល្លារអាមេរិក ត្រូវបានកាត់បន្ថយ។ ថ្មីៗនេះ លោក Jean-Claude Juncker ប្រធានគណៈកម្មការអ៊ឺរ៉ុបបានគាំទ្រ ភាពមិនសមហេតុផលរបស់ក្រុមហ៊ុនអឺរ៉ុបដែលធ្វើធុរៈកិច្ចជាមួយគ្នា គិតជាដុល្លារអាមេរិក។ ប្រទេសចិន បានបន្តការកំណត់ថ្លៃប្រេងឆៅសម្រាប់ពេលអនាគត ដោយចុះកិច្ចសន្យាជាលុយយ៉ន់។ ថ្មីៗនេះ ថ្នាក់ដឹកនាំរដ្ឋាភិបាលផ្នែកហិរញ្ញវត្ថុនៅប្រទេសបារាំង និងរុស្ស៊ី បានប្រកាសពីគម្រោង ឬបំណង ក្នុងការដកចេញពីការពឹងផ្អែកប្រាក់ដុល្លារអាមេរិកជាឧបករណ៍ហិរញ្ញវត្ថុ។

ការកាត់បន្ថយការប្រើប្រាស់ដុល្លារអាមេរិកដែលជារូបិយប័ណ្ណពិភពលោកនេះ អាចប្រើរយៈពេលយូរ។ និន្នាការនេះអាចនឹងប៉ះពាល់ដល់អត្ថប្រយោជន៍របស់អាមេរិកដែលកំពុងមាន៖ ស្ថានភាពរូបិយវត្ថុនៃប្រាក់បម្រុងគឺជួយដល់គោលនយោបាយរូបិយវត្ថុរបស់អាមេរិក ម្យ៉ាងវិញទៀត នៅក្នុងកំឡុងពេលមានវិបត្តិ សាច់ប្រាក់របស់ពិភពលោករបស់ប្រទេសនានានឹងហូរចូលមកអាមេរិកដែលជាស្ថានសួគ៌ប្រកបដោយសុវត្ថិភាព។

ដោយសារតែស្ថានភាពរបស់ដុល្លារអាមេរិក បានធ្វើអោយតម្លៃរបស់វាខ្ពស់នៅក្នុងទីផ្សារពិភពលោក ការប្រែប្រួលណាមួយរបស់ដុល្លារអាមេរិក អាចជួយដល់កម្ពុជា តាមរយៈការធ្វើអោយលុយរបស់ខ្លួនដែលទាក់ទងនឹងប្រាក់ដុល្លារនោះ និងការនាំចេញរបស់កម្ពុជាមានលក្ខណៈប្រកួតប្រជែងជាងមុន។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ កំនើនផ.ស.ស របស់ប្រ៊ុយណេ គណនីបច្ចុប្បន្ន និងការបញ្ជាទិញគ្រឿងម៉ាស៊ីន របស់ជប៉ុន សមតុល្យពាណិជ្ជកម្មរបស់ហ្វីលីពីន និងផលិតកម្ម ឧស្សាហកម្មរបស់ម៉ាឡេស៊ី។

ខាងក្រោមនេះ គឺជាប្រតិទិនពេញលេញដែលបង្ហាញពីទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងធ្វើការបង្ហាញនៅសប្តាហ៍បន្ទាប់៖

<u>ថ្ងៃច័ន្ទ ទី ០៨ ខែតុលា</u>

- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសប្រ៊ុយណេ សម្រាប់ខែមិថុនា និងកក្កដា
- អត្រាកំណើនផ.ស.ស របស់ប្រទេសប្រ៊ុយណេ សម្រាប់ត្រីមាសទី២ ឆ្នាំ២០១៨
- ទិន្នន័យការលក់រាយ របស់ប្រទេសឥណ្ឌូនេស៊ី សម្រាប់ខែសីហា
- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសតៃវ៉ាន់ សម្រាប់ខែកញ្ញា

<u>ថ្ងៃអង្គារ ទី ០៩ ខែតុលា</u>

- គណនីចរន្តរបស់ប្រទេសជប៉ុន សម្រាប់ខែសីហា
- ទិន្នន័យការបញ្ជាទិញឧបករណ៍ម៉ាស៊ីនរបស់ប្រទេសជប៉ុន សម្រាប់ខែកញ្ញា
- អត្រាអតិផរណារំពឹងទុករបស់សហរដ្ឋអាមេរិក សម្រាប់ខែកញ្ញា

<u>ថ្ងៃពុធ ទី ១០ ខែតុលា</u>

- ទិន្នន័យការបញ្ជាទិញម៉ាស៊ីន របស់ប្រទេសជប៉ុន សម្រាប់ខែសីហា
- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសហ្វីលីពីន សម្រាប់ខែសីហា
- ទិន្នន័យការវិនិយោគដោយផ្ទាល់ពីបរទេស របស់ប្រទេសហ្វីលីពីន សម្រាប់ខែសីហា
- សន្ទស្សន៍តម្លៃសម្រាប់អ្នកផលិត របស់សហរដ្ឋអាមេរិក សម្រាប់ខែកញ្ញា

<u>ថ្ងៃព្រហស្បតិ៍ ទី ១១ ខែតុលា</u>

- គណនីចរន្តរបស់ប្រទេសកូរ៉េខាងត្បូង សម្រាប់ខែសីហា
- សន្ទស្សន៍តម្លៃសម្រាប់អ្នកផលិត របស់ប្រទេសជប៉ុន សម្រាប់ខែកញ្ញា
- ទិន្នន័យផលិតកម្មឧស្សាហកម្មរបស់ប្រទេសម៉ាឡេស៊ី សម្រាប់ខែសីហា
- អត្រាអតិផរណារបស់សហរដ្ឋអាមេរិក សម្រាប់ខែកញ្ញា
- ទិន្នន័យការអះអាងភាពគ្មានការងារធ្វើ របស់សហរដ្ឋអាមេរិក ថ្ងៃទី០៦ ខែកញ្ញា

<u>ថ្ងៃសុក្រ ទី ១២ ខែតុលា</u>

- អត្រានិកម្មភាពរបស់ប្រទេសកូរ៉េខាងត្បូង សម្រាប់ខែកញ្ញា
- ផ.ស.ស របស់ប្រទេសសិង្ហបុរី សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៨
- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសចិន សម្រាប់ខែកញ្ញា
- ទិន្នន័យការលក់រាយរបស់ប្រទេសម៉ាឡេស៊ី សម្រាប់ខែសីហា
- ទិន្នន័យការលក់រាយរបស់ប្រទេសសិង្ហបុរី សម្រាប់ខែសីហា
- តម្លៃសម្រាប់ការនាំចេញ និងការនាំចូលរបស់សហរដ្ឋអាមេរិក សម្រាប់ខែកញ្ញា
- កិច្ចប្រជុំប្រចាំឆ្នាំរបស់ប្រទេសឥណ្ឌូនេស៊ីជាមួយស្ថាប័នមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក ៕

******************************